

# ការការពារសហគមន៍

# ការការពារជម្ងឺគ្រុនចាញ់

## មាគ៌ាឆ្ពោះទៅរកភាពធន់មាំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍

CAMBODIAN RED CROSS

International Federation
of Red Cross and Red Crescent Societies
**Saving lives, changing minds.**



តុន ឯងកំពុងមើលអីហ្នឹង?
មើលណ៎ែ! កូនដង្កូវទឹកដែលកើតមកពីពងដង្កូវទឹក កំពុងកំមីកររើកៗក្នុងទឹក
...ហើយកូនដង្កូវទឹកទាំងនេះនឹងក្លាយជាមូសឆាប់ៗនេះ...
...ជាមូសដែលអាចបណ្តាលឲ្យយើងកើតជម្ងឺគ្រុនចាញ់ ប្រសិនបើវាមានផ្ទុកមេរោគគ្រុនចាញ់ហើយមកខាំយើង
អូហ៎ បើមូសចេញមកពីទឹក...
...យើងគួរតែសំអាតវត្ថុណាដែលអាចដក់ទឹកនៅជុំវិញផ្ទះយើងឲ្យអស់ទៅអញ្ចឹង។
ឯងមានដឹងទេ ពេលយើងកើតជម្ងឺគ្រុនចាញ់ តើយើងអាចមានអាការៈបែបណាខ្លះ? នណាៗក៏អាចកើតជម្ងឺនេះដែរ។
ខ្ញុំដឹងថាយើងនឹងមានជម្ងឺគ្រុនក្តៅផងដែរ...
ឈឺក្បាល
ឈឺសន្លាក់ឆ្អឹង
ក្អួតចង្អោរ
មិនចង់ហូបបាយ ឬមិនចង់ផឹកទឹក
វិលមុខ


ការធ្វើតេស្តរកមេរោគគ្រុនចាញ់គឺងាយទេ ប៉ុន្តែយើងត្រូវតែទៅមណ្ឌលសុខភាព ពេលណាយើងសង្ស័យថាមានជម្ងឺគ្រុនចាញ់។
គេមានថ្នាំព្យាបាលវាឲ្យជាសះស្បើយ បើយើងប្រើវាត្រឹមត្រូវ និងទាន់ពេលវេលា។
តោះ នាំគ្នានិយាយអំពីវិធីកុំឲ្យមូសខាំយើងបាន
ពុកម៉ែចងមុងឲ្យខ្ញុំពេលដែលខ្ញុំដេកលក់ ដើម្បីការពារកុំឲ្យមូសខាំ...
...មុងនេះជួយការពារយើងកុំឲ្យមូសចូលមកខាំយើង បានពេលដែលយើងកំពុងដេកលក់
មើលនែ៎ បង្អួចក៏មានសំណាញ់ក្រណាត់សម្រាប់ ទប់ស្កាត់មូសកុំឲ្យចូលមកក្នុងផ្ទះបាន។
អុហ៎...ក្លិនអីចេះ? ដូចក្លិនធូបរបស់ពុកអញ្ចឹង!
អាហ៎! ក្លិនធូបមូសហ្នឹងណា។ មូសវាមិនចូលចិត្តក្លិនហ្នឹងទេ ដូច្នេះវាហើរចេញពេលវាធុំក្លិននេះ។
ខ្ញុំចូលចិត្តក្លិនស្ព្រាយបាញ់មូសនេះ ប៉ុន្តែមូសមិនចូលចិត្តទេ ហើយវាក៏នឹងមិនចូលមកក្បែរដែរ។ មេឃចាប់ផ្តើមងងឹតហើយ បាញ់វាបន្តិចសិន...
បើមូសមើលមិនឃើញស្បែកយើង
នោះវាមិន មិនអាចខាំយើងបានទេ។
ចាំមើលមើល តើថ្នាំមូសនេះមានប្រសិទ្ធភាពមិនឲ្យមូសខាំបានយូរប៉ុណ្ណា។

ខាងក្រោមនេះគឺជាចំណេះដឹងមួយចំនួនដែលគួរតែចងចាំទាក់ទងនឹងជម្ងឺគ្រុនចាញ់។ សូមស្វែងយល់អំពីជម្ងឺគ្រុនចាញ់ឲ្យបានល្អិតល្អន់ ព្រោះថាវាអាចជួយអ្នក និងគ្រួសារអ្នកបាន!

- ជម្ងឺគ្រុនចាញ់ គឺជាប្រភេទជម្ងឺដែលឆ្លងតាមរយៈមូសដែលផ្ទុកមេរោគគ្រុនចាញ់ខាំ។
- មនុស្សគ្រប់រូបអាចមានហានិភ័យក្នុងការកើតជម្ងឺគ្រុនចាញ់។ កុមារអាយុក្រោម៥ឆ្នាំ និងស្ត្រីមានផ្ទៃពោះមានអត្រាគ្រោះថ្នាក់ខ្ពស់ដល់ការបាត់បង់ជីវិតពេលមានជម្ងឺគ្រុនចាញ់នេះ។
- រោគសញ្ញាចម្បងនៃជម្ងឺគ្រុនចាញ់គឺគ្រុនក្តៅ ប៉ុន្តែក៏មានអាការៈផ្សេងៗទៀតដែរដូចជា:

  –ឈឺក្បាល
  –ឈឺសន្លាក់ឆ្អឹង
  –ក្អួតចង្អោរខ្លាំង
  –មិនចង់ហូបបាយ ឬមិនចង់ផឹកទឹក
  –ប្រកាច់/វិលមុខ

- ការព្យាបាលជម្ងឺគ្រុនចាញ់ទាន់ពេលវេលាអាចសង្គ្រោះជីវិតបាន។ អ្នកណាក៏ដោយដែលមានជម្ងឺគ្រុនក្តៅត្រូវតែយកមកព្យាបាលនៅមណ្ឌលសុខភាពក្នុងរយៈពេល២៤ម៉ោង។ អ្នកជម្ងឺគ្រុនចាញ់ត្រូវតែព្យាបាលឲ្យបានគ្រប់ជំហានរបស់វា។
- ប្រើមុងជ្រលក់ថ្នាំនៅពេលគេង អាចជួយការពារកុំឲ្យមូសផ្ទុកមេរោគគ្រុនចាញ់ខាំបាន។
- វិធីការពារកុំឲ្យមូសខាំផ្សេងៗទៀតមានដូចជា:

  - ដាក់សំណាញ់ល្អិតបាំងនៅតាមបង្អួច និងទ្វារ
  - ប្រើប្រាស់ខោអាវវែងៗ
  - ដុតធូបមូស
  - លាបថ្នាំមូសលើស្បែកដើម្បីការពារកុំឲ្យមូសខាំ

- រក្សាអនាម័យបរិស្ថានរស់នៅជុំវិញ និងត្រូវធានាថាមិនមានទឹកដក់នៅជិតផ្ទះ



សម្រាប់ព័ត៌មានបន្ថែមអំពីជម្ងឺគ្រុនចាញ់ សូមចូលមើលក្នុងគេហទំព័រ: www.ifrc.org/malaria

International Federation of
Red Cross and Red Crescent Societies
South-East Asia regional delegation

Community Safety and Resilience Unit
Ocean Tower I, 170/11-12 Sukhumvit soi 16, Klong-toey
10110 Bangkok, Thailand
T: +662 661 8201 F: +662 661 9322
E: thailand.regionaloffice@ifrc.org

Norwegian **Red Cross**

International Federation
of Red Cross and Red Crescent Societies
www.ifrc.org Saving lives, changing minds.